# មជ្ឈមណ្ឌលឯកសារកម្ពុជា

*ការស្រង់មតិសាធារណៈជនជុំវិញការកាត់ទោសមនុស្សបន្ថែម*
*ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា - តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម*

## **ភាគព្វកិច្ចរបស់ជនរងគ្រោះចំពោះការពិត និង យុត្តិធម៌**

*«វាមានសារៈសំខាន់ណាស់ដែលជនរងគ្រោះគឺជាភាគីមួយ*
*ព្រោះជនរងគ្រោះតាមរយៈនេះអាចបញ្ចេញសម្លេងដូចគ្នាទៅនឹងភាគីកម្ពុជា និង ភាគីអន្តរជាតិ*
*[របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា]»*

*ឆាំង យុ*

*អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាតុលាការពិសេសមួយសម្រាប់កាត់ទោសមេដឹកនាំជាន់ខ្ពស់ និង អ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរកាលពីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ។ តុលាការពិសេសនេះ ឬ ដែលយើងហៅថា តុលាការកាត់ទោសខ្មែរក្រហម បានចាប់ផ្តើមបំពេញការងាររបស់ខ្លួន នៅក្នុងឆ្នាំ២០០៦ និង ត្រូវបានបង្កើតឡើងរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ ។ តុលាការនេះមានអាយុកាលតែក្នុងរយៈពេលកំណត់មួយប៉ុណ្ណោះ ។ តុលាការនេះមានសហព្រះរាជអាជ្ញាពីររូប ដែលម្នាក់ជាជនជាតិកម្ពុជា និង ម្នាក់ទៀតជាជនជាតិបរទេស ។ សហព្រះរាជអាជ្ញាទាំងពីរនេះ បានធ្វើការចោទប្រកាន់ និង ឃុំខ្លួនបណ្តោះអាសន្ននូវមេដឹកនាំខ្មែរក្រហមកាន់តំណែងខ្ពស់ចំនួន៥រូប ។ មេដឹកនាំម្នាក់នៅក្នុងចំណោមនេះនឹងត្រូវកាត់ទោសក្នុងរយៈពេលប៉ុន្មានខែខាងមុខ ។ មេដឹកនាំ៤រូបទៀតកំពុងស្ថិតនៅក្រោមការស៊ើបអង្កេត និង មិនទាន់បានបញ្ជូនទៅកាត់ទោសនៅឡើយ ។*

*សហព្រះរាជអាជ្ញាខាងបរទេស ចង់ឲ្យតុលាការនេះស៊ើបអង្កេតមនុស្សប្រមាណពី៥ ទៅ១០នាក់បន្ថែមទៀត ដែលអ្នកទាំងនេះត្រូវគេជឿជាក់ថា មានតំណែងនៅក្នុងថ្នាក់ដឹកនាំខ្មែរក្រហម និង បានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែរ បើទោះបីជាមិនកាន់តំណែងខ្ពស់ដូចអ្នកទាំង៥រូបកំពុងត្រូវឃុំខ្លួនបច្ចុប្បន្ននេះក៏ដោយ ។ សហព្រះរាជអាជ្ញាខាងកម្ពុជា បានជំទាស់ទៅនឹងការកាត់ទោសមនុស្សបន្ថែមទៀតនេះ ដោយគិតថា ពេលវេលា និង ថវិកាដែលមានកំណត់នេះ គួរតែប្រើប្រាស់សម្រាប់ការកាត់ទោសអ្នកទាំង៥រូបដែលកំពុងជាប់ឃុំខ្លួនរួចមកហើយនេះវិញ ។ សហព្រះរាជអាជ្ញាខាងកម្ពុជា ក៏បានសម្តែងនូវការព្រួយបារម្ភថា ការកាត់ទោសមនុស្សច្រើនជាង៥រូប នឹងអាចបង្កឲ្យមានចលាចល អំពើហឹង្សា និង ការបែកបាក់ នៅក្នុងសង្គម ។*

សំណួរខាងក្រោម គឺធ្វើឡើងដើម្បីស្រង់មតិសាធារណៈជន ជុំវិញការកាត់ទោសមនុស្សបន្ថែមទៀតនេះ៖

១. តើអ្នកធ្លាប់បានដឹងអំពីតុលាការខ្មែរក្រហមឬទេ? ប្រសិនបើអ្នកធ្លាប់ដឹង តើអ្នកដឹងអំពីតុលាការនេះកម្រិតណា?

☐ មិនធ្លាប់ដឹង ☐ ដឹងតិចតួច ☐ ដឹងល្មម ☐ ដឹងច្រើន

២. តើអ្នកយល់ថា អតីតមេដឹកនាំខ្មែរក្រហមគួរតែត្រូវកាត់ទោសដោយតុលាការខ្មែរក្រហមឬទេ?

☐ យល់ស្រប ☐ មិនយល់ស្រប

ប្រសិនបើអ្នកយល់ស្រប តើអ្នកគាំទ្រការកាត់ទោសនេះកម្រិតណា?

☐ តិចតួច ☐ ល្មម ☐ ច្រើន

៣. តើអ្នកយល់ថា តុលាការខ្មែរក្រហមគួរកាត់ទោសមេដឹកនាំខ្មែរក្រហមតែចំនួន៥រូបដែលកំពុងស្ថិតនៅក្រោមការឃុំឃាំងនេះ ឬ គួរតែកាត់ទោសមនុស្សចំនួន៥-១០រូបបន្ថែមទៀត?

☐ ៥រូប ☐ ៥-១០រូបបន្ថែម

តើអ្នកគាំទ្រចម្លើយរបស់អ្នកកម្រិតណា?

☐ តិចតួច ☐ ល្មម ☐ ច្រើន

៤. តើអ្នកគិតថា បញ្ហាថវិការបស់តុលាការគួរតែជាកត្តាសំខាន់មួយនៅក្នុងការសម្រេចកាត់ទោសមនុស្សចំនួនប៉ុន្មានរូបឬទេ?

☐ យល់ស្រប ☐ មិនយល់ស្រប

៥. ប្រសិនបើតុលាការខ្មែរក្រហមកាត់ទោសមនុស្សច្រើនជាង៥រូប ដែលកំពុងត្រូវឃុំឃាំងបណ្ដោះអាសន្នសព្វថ្ងៃ តើអ្នកយល់ថា អាចបង្កឲ្យមានអស្ថេរភាព ឬ អំពើហិង្សា នៅក្នុងសង្គមឬទេ?

☐ អស្ថេរភាព ឬ អំពើហិង្សា ☐ មិនមានអស្ថេរភាព ឬ អំពើហិង្សាទេ

៦. តើអ្នកគិតថា មុននឹងធ្វើការសម្រេចថាតើគួរកាត់ទោសមនុស្សបន្ថែមទៀតឬអត់ តុលាការកាត់ទោសខ្មែរក្រហមគួរតែកាត់ទោសអ្នកទាំង៥រូប ដែលកំពុងត្រូវឃុំខ្លួនបណ្ដោះអាសន្ននេះឲ្យរួចសិន?

☐ យល់ស្រប ☐ មិនយល់ស្រប

៧. ប្រសិនបើតុលាការខ្មែរក្រហមកាត់ទោសតែមេដឹកនាំខ្មែរក្រហមចំនួន៥រូប តើអ្នកយល់ថាតុលាការខ្មែរក្រហមបាននាំមកនូវយុត្តិធម៌គ្រប់គ្រាន់សម្រាប់កម្ពុជាឬទេ?

☐ គ្រប់គ្រាន់ ☐ មិនគ្រប់គ្រាន់

ប្រសិនបើលោកអ្នកមានបំណងផ្ដល់ព័ត៌មានផ្ទាល់ខ្លួន សូមបំពេញខាងក្រោមនេះ (មិនបំពេញក៏បាន)៖

ឈ្មោះ................................ អាយុ ......... ភេទ ..........

អាស័យដ្ឋាន.................................................................

លេខទូរស័ព្ទ.................................................................

មុខរបរ......................................................................


សូមផ្ញើចម្លើយរបស់អ្នកមកកាន់៖

លោក ជី ទេរិទ្ធិ

ប្រធានគម្រោងជួយជនរងគ្រោះ

មជ្ឈមណ្ឌលឯកសារកម្ពុជា

ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ

ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥

ទូរស័ព្ទចល័ត ០១២ ៧៩៥ ៣៥៣

ទូរសារលេខ ០២៣ ២១០ ៣៥៨

អ៊ីមែល truthterith.c@dccam.org

គេហទំព័រ www.dccam.org

www.cambodiatribunal.org